# តម្រាព្រៃនិងប្រផ្នូលផ្សេងៗ

# ជាទំនាយទឹកភ្លៀង

## ភាគទី១

ប្រមូលចងក្រងដោយៈ

ភិក្ខុមេត្តាសារោ ព្រហ្ម សូវង្ស

ព.ស.២៥៥៦ គ.ស.២០១៣

# អារម្ភកថា

ខ្ញុំព្រះករុណាអាត្មាភាព មានចិត្តរំភើបរីករាយឥត ឧបមា ដោយបានរៀបចំនូវកូនសៀវភៅដ៏តូចមួយ មាន ឈ្មោះថា តម្រាព្រៃនិងប្រផ្នូលផ្សេងៗជាទំនាយទឹកភ្លៀង ដែល លោកអ្នកកំពុងអាននេះ បានសម្រេចជាស្ថាពរ ដើម្បី ទុកជាប្រយោជន៍ដល់ខេមរជនទាំងឡាយ គ្រាន់ពិចារ ណា។ មូលហេតុដែលនាំឱ្យខ្ញុំរៀបចំប្រមូលចងក្រងនូវ កូនសៀវភៅនេះឡើង គឺដោយខ្ញុំព្រះករុណាអាត្មា ភាព បានឃើញនូវតម្រាដែលជាស្នាដៃរបស់អ្នកស្រី ពេជ្រ សល់ បាននិយាយអំពីទំនៀមរបស់ជនជាតិខ្មែរ ដែលមានតាំង ពីយូរលង់ណាស់មកហើយ។

លុះខ្ញុំព្រះករុណាអាត្មាភាព បានអាននូវតម្រានេះ រួចហើយ ធ្វើឱ្យខ្ញុំព្រះករុណាអាត្មាភាព មានគំនិតថានឹង រៀបចំយកស្នាដៃដ៏ប្រពៃថ្លៃថ្លានេះ ទៅបោះពុម្ពជាកូន សៀវភៅមួយ ដើម្បីទុកជាសម្បត្តិវប្បធម៌ជាតិរបស់ខ្មែរ និងដើម្បីបង្ហាញនូវទំនៀម ដែលជាអត្តសញ្ញាណជាតិ របស់ខ្លួនផង។ ម្យ៉ាងទៀតបើទោះជាការចំណាំតៗគ្នា

របស់ចាស់ទុំ ពុំសូវស្របជាមួយនិងវិទ្យាសាស្ត្របច្ចុប្បន្នក៏ដោយ ក៏ប៉ុន្តែនេះគឺជាទំនៀមរបស់ដូនតាខ្មែរ ដែលយើងមិនគួរឱ្យបាត់បង់ទេ ត្រូវតែនាំគ្នាថែរក្សាឱ្យបានគង់វង្ស។ ខ្ញុំព្រះករុណាអាត្មាភាព ក៏ចាប់ផ្តើមប្រមូលយកមករៀបចំជាកូនសៀវភៅ ហើយក៏បានសាកសួរចាស់ទុំបន្ថែមខ្លះទៀត យកមកបញ្ចូលជាមួយស្នាដៃរបស់អ្នកស្រី ពេជ្រ សល់ ដែលបានបោះពុម្ពតាំងពីទសវត្ស៦០មកស្រាប់។ គាត់ជូនឧបាសក សែម សុទ្ធ រស់នៅភូមិស្តើងជ័យ ឃុំ ស្តើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម បានដឹងដំណឹងនេះក៏បានឆ្លៀតសរសេរនូវរឿង តម្រាព្រៃ និងប្រផ្នូលទឹកភ្លៀង តាមការចេះចាំតៗគ្នារបស់គាត់ពីជំនាន់ដើម ផ្ញើមកឱ្យខ្ញុំ ដាក់បញ្ចូលឱ្យកាន់តែសម្បូរឡើងថែមទៀត។ ខ្ញុំព្រះករុណាអាត្មាភាព សូមអំពាវនាវដល់ព្រះករុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមចាស់ព្រឹទ្ធាចារ្យគ្រប់រូប បើសិនជាបានចេះចាំនូវតម្រាព្រៃ ឬប្រផ្នូលទឹកភ្លៀងត្រង់ចំណុចណាដែលមិនបាននិយាយក្នុងសៀវភៅនេះ សូមនិមន្តនិងអញ្ជើញសរសេរផ្ញើមកខ្ញុំព្រះករុណាអាត្មាភាព ដើម្បីបានបោះពុម្ពជាភាគបន្តទៀត។ ប្រសិនបើជាកូន

សៀវភៅនេះ មានចំណុចណាភ្លាំងភ្លាត់ ខ្ញុំសូមទទួលយក
នូវមតិកែលម្អរបស់លោកអ្នកសប្បុរសទាំងឡាយ។

វត្តព្រះពុទ្ធឃោសាចារ្យ ទួលតាហោ ថ្ងៃទី ១៥ កើត ខែ មាឃ ព.ស.២៥៥៦
គ.ស.២០១៣

ភិក្ខុមេត្តាសារោ ព្រហ្ម សូវង្ស

## មាតិកា

រឿង ទំព័រ

១.តម្រាព្រៃ និងប្រផ្នូលផ្សេងៗជាទំនាយទឹកភ្លៀង........១
២.តម្រាកំណត់ចំណាំរបស់កសិករខ្មែរ......................២៥

## ឯកសារពិគ្រោះ

១.សៀវភៅកម្ពុជសុរិយា។

២.សេចក្តីអធិប្បាយរបស់ លោក សែម សុទ្ធ។

៣.ការចំណាំតៗគ្នារបស់ចាស់ទុំ។

## បច្ចេកទេសកុំព្យូទ័រ

លោក យី ចាន់សារឿន

# តម្រាព្រៃនិងប្រផ្នូលផ្សេងៗជាទំនាយទឹកភ្លៀង

អ្នកស្រី ពេជ្រ-សល់ តែងនិងរៀបរៀង

នៅស្រុកខ្មែរយើង តាំងពីបុរាណកាលរៀងមក អ្នកធ្វើស្រែធ្វើចំការ និងអ្នកប្រកបរបរខាងដំណាំដាំដុះផ្សេងៗច្រើនទីពឹងតែទៅលើទឹកភ្លៀង ដែលជាធម្មជាតិបណ្តាលមានឡើងក្នុងមួយឆ្នាំម្តង តាមរដូវកាល ដូចយើងបានដឹងស្រាប់ហើយថា ពិតមែនតែមានភ្លៀង តែទឹកភ្លៀងពុំបានបង្អុរចុះឲ្យបានទៀងទាត់រាល់ឆ្នាំទេ ឆ្នាំខ្លះក៏ក្រមានភ្លៀងធ្លាក់ ឆ្នាំខ្លះក៏ឆាប់មានភ្លៀងធ្លាក់ ហើយទឹកភ្លៀងធ្លាក់នោះទៀត ក៏ពុំមានចំនួនទៀងទាត់ឡើយ បើឆ្នាំណាមានភ្លៀងធ្លាក់មកល្មមគ្រប់គ្រាន់ នោះដំណាំដាំដុះរបស់អ្នកស្រុកក៏បានផលបរិបូរ។ បើឆ្នាំណាមានភ្លៀងធ្លាក់តិចពេកឬច្រើនពេក នោះផលដំណាំក៏មិនសូវបានបរិបូរ។ តែសូមជំរាបថា អ្នកស្រុកខ្មែរយើងមិនមែនចេះតែនាំគ្នាធ្វើរបរទាំងងងឹតងងុលនោះទេ ព្រោះថានៅក្នុងលោកនេះ កាលនឹងធ្វើឲ្យកើតឡើង សុទ្ធតែមានអ្វីមួយជាហេតុសម្រាប់សម្គាល់មុនជានិច្ច។ ហេតុភេទនេះ ជួនកាលបណ្តាលមក

ពីសត្វ ជូនកាលបណ្ដាលមកពីធម្មជាតិ ដែលអ្នកស្រុកតែងតែសំគាល់ ហើយចំណាំតៗគ្នារហូតមក។ ឯរឿងការចំណាំនេះទៀត ក៏ពុំមែនចេះតែចំណាំដូចគ្នា គ្រប់ៗជនបទនោះទេ គឺថាអ្នកស្រុកនេះ គេសំគាល់តាមសត្វនេះ ឬភេទអាកាសធាតុបែបនេះ អ្នកស្រុកនោះគេសំអាងលើប្រផ្នូលរបស់សត្វនោះ ឬភេទធម្មជាតិបែបនោះ ទៅតាមទម្លាប់អ្នកស្រុករបស់គេ។

ដូចជានៅ ឃុំឫស្សីព្រៃ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ កាលពីដើមមក អ្នកស្រុកតែងចំណាំដើមឈើដែលមានស្នាមខ្លាក្រចៅ។ នៅក្នុងស្រុកនេះមានភ្នំតូចមួយដុះលយចូលទៅក្នុងព្រៃនាម ដែលនៅខាងត្បូងភ្នំ គេហៅថា ភ្នំក្ដាម។ នៅលើភ្នំនេះមានអ្នកតាមួយពូកែណាស់ អ្នកស្រុកតែងគោរពរាប់អានជាងគេ។ នៅក្នុងព្រៃនាមនោះចម្ងាយប្រហែល២០០ម៉ែត្រពីមាត់ព្រៃ និងនៅក្បែរផ្លូវលំសម្រាប់ដើរពីភូមិទៅកាន់ភ្នំ មានក្ដុលមួយដើមដែលអ្នកស្រុកតែងតែទៅមើលស្នាមខ្លាក្រចៅជារៀងរាល់ឆ្នាំ។ ជួនកាលមានស្នាមខ្លាក្រចៅនៅទាប ជួនកាលស្នាមខ្លាក្រចៅនៅខ្ពស់

ពីដីហើយគេតែងចំណាំថា បើស្នាមខ្លាក្រចៅនៅត្រឹមណា នោះទឹកនឹងឡើងត្រឹមស្នាមនោះជាប្រាកដ ។

ការណ៍ដែលកើតឲ្យចេះចំណាំដូច្នេះ គឺមកពីអ្នកតាដែលនៅលើភ្នំក្តាមនោះ។ តែដល់រដូវដើមឆ្នាំ អ្នកស្រុកតែងតែនាំគ្នាធ្វើបុណ្យឡើងអ្នកតា ដើម្បីសុំសេចក្តីសុខ និងដើម្បីសួរអំពីទឹកធំឬតូចផង។ ពេលជាន់រូប អ្នកតាតែងប្រាប់អ្នកស្រុកថា "បើចង់ដឹងកម្រិតទឹកឆ្នាំនេះ ត្រូវចាំមើលស្នាមក្រចកសេះរបស់យើងនៅនឹងដើមក្តុល បើឃើញស្នាមត្រឹមកំពស់ណា ទឹកនឹងឡើងត្រឹមស្នាមនោះឯង"។ បន្ទាប់មកអ្នកស្រុកក៏នាំគ្នាហៅព្រៃរនាមដែលមានដើមក្តុលខ្លាក្រចៅនោះថា "ព្រៃកម្រិតទឹក" ជាប់រហូតមកដល់សព្វថ្ងៃ។ ប៉ុន្តែឥឡូវនេះ គេឈប់ជឿទៅហើយ ព្រោះគេលែងឃើញស្នាមខ្លាក្រចៅដូចមុនៗទៀត។

ឥឡូវនេះ ដើម្បីដឹងថាក្នុងឆ្នាំថ្មីមានភ្លៀងច្រើនឬតិចជាងឆ្នាំមុន អ្នកស្រុកប្រើមធ្យោបាយមួយផ្សេងទៀតដែលគេបានពិសោធន៍ឃើញថាទៀងដែរ គឺគេយកទឹកភ្លៀងដើមឆ្នាំដែលធ្លាក់មុនដំបូងបង្អស់ និងទឹកអណ្តូង ស្ទឹងឬ

ទន្លេយើងធម្មតា(១) ឱ្យមានចំនួនប៉ុនគ្នា មកថ្លឹងទូគ្នាមើល បើទឹកភ្លៀងធ្ងន់ជាងទឹកទន្លេ គេដឹងថាឆ្នាំថ្មីនឹងមានភ្លៀងបង្អុរចុះច្រើនជាងឆ្នាំចាស់។ បើទឹកភ្លៀងស្រាលជាង គេថាឆ្នាំថ្មីនេះទឹកតូច ហើយទឹកភ្លៀងក៏តិចជាងឆ្នាំចាស់។

ដល់រដូវជំនន់ គេត្រូវចាំមើលហ្វូងផ្សោតប្រដេញគ្នាតាមទន្លេវិញ គឺថា បើវាប្រដេញគ្នាច្រាស់ខ្សែទឹកហូរ គេដឹងថា ទឹកនឹងនៅឡើងតទៅទៀត តែបើវាប្រដេញគ្នាបណ្ដោយតាមខ្សែទឹកវិញ គេដឹងថា ទឹកនឹងស្រកចុះវិញ ហើយមិនឡើងទៀតទេ ព្រោះសត្វផ្សោតវាដេញតាមស៊ី

---

(១)នៅភូមិសំប៉ាន ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្ដាល អ្នកស្រុកធ្វើការពិសោធន៍ ដោយថ្លឹងទឹកដែរ តែគេត្រូវធ្វើដូច្នេះ ៖ នៅថ្ងៃដែលចិនសែនក្បាលទឹក (គឺនៅថ្ងៃទី ៥ ខែទី ៥ ចិន ត្រូវនឹងខែជេស្ឋខ្មែរ) នៅពេលថ្ងៃត្រង់ គេទៅដងទឹកពីទន្លេ យកមកដាក់ដបទុក ។ ដល់ឆ្នាំមុខ នៅថ្ងៃខែនឹងពេលដដែល គេទៅដងទឹកពីទន្លេមកទៀត គេយកទឹកឆ្នាំដែលកន្លងទៅហើយ នឹងទឹកឆ្នាំថ្មីឱ្យមានចំនួនប៉ុនគ្នា ហើយគេថ្លឹងទូគ្នាមើល។ បើទឹកឆ្នាំថ្មីស្រាលជាងឆ្នាំចាស់ គេថាទឹកឆ្នាំថ្មីតូចជាងឆ្នាំចាស់ បើទឹកឆ្នាំថ្មីធ្ងន់ជាងឆ្នាំចាស់ គេថាទឹកឆ្នាំថ្មីធំជាងឆ្នាំចាស់ ។ ឯរឿងថ្លឹងនេះ មិនបាច់ឱ្យជញ្ជីងបះខ្លាំងទេ តែល្អៀងបន្តិចក៏គេទុកជាបានការហើយ។ តាមការចំណាំរបស់អ្នកស្រុកសម្គាល់ដូច្នេះ ច្រើនទៀងជាងពិធីដទៃ ។

ត្រីដែលវាឡើងនិងចុះតាមទឹក។ នៅមានការចំណាំមួយបែបទៀតដែលអ្នកស្រុកនៅជឿដល់សព្វថ្ងៃនៅឡើយ គឺគេចំណាំតាមសត្វក្រពើ គឺថា ឱ្យតែដល់រដូវទឹកជំនន់ហើយ អ្នកស្រុកចាំស្តាប់សំឡេងក្រពើរោទ៍នៅឯមាត់ពាមនៅពេលព្រលប់ម្តង នៅពេលកណ្តាលអធ្រាត្រម្តង។ បើគេឮក្រពើរោទ៍ពីព្រលប់ ហើយរោទ៍តមាត់គ្នាដេញពីមាត់ពាមឡើងទៅលើ គេដឹងថាទឹកឡើងទៀត។ បើគេឮក្រពើរោទ៍នៅពេលពីអធ្រាត្រទៅពេលមាន់រងាវ ហើយរោទ៍តគ្នាពីលើចុះទៅរកមាត់ពាមវិញ គេសំគាល់ថាទឹកនឹងស្រកចុះ។ ម៉្យាងទៀត លោក ជឹម-ឈុំ ដែលជាសមាជិករបស់ក្រុមជំនុំទំនៀមទម្លាប់ប្រចាំស្រុកសណ្តាន់ បានឲ្យការណ៍ថែមទៀតថា សត្វក្រពើខ្លាចវល្លិ៍ប្រេងណាស់ ដូច្នេះហើយបានជាអ្នកស្រុកតែងយកវល្លិ៍នេះក្រវាត់ចង្កេះ នៅពេលដែលគេត្រូវការងូតទឹក ក្រពើនឹងមិនហ៊ានមកជិតឡើយ។

នៅស្រុកដដែលនេះ មានជំនឿម៉្យាងទៀត គឺគេសំគាល់នឹងក្រឡា ស-ខ្មៅ នៅកន្ទុយនៃសត្វត្រកួតខ្យល់ [១] ដែលជាតម្រាព្រៃសម្រាប់ឲ្យដំណឹងអំពីទឹកភ្លៀងដែរ។

---

១.ជាត្រកួតម៉្យាង មានមាឌតូចប៉ុនសត្វជាស ។

គេកំណាត់ត្រង់គល់កន្ទុយជាដើមឆ្នាំ ត្រង់កណ្ដាលកន្ទុយជាកណ្ដាលឆ្នាំ និងចុងកន្ទុយជាចុងឆ្នាំ។ ធម្មតាកន្ទុយត្រកួតតែងមានគន្លាក់ស គន្លាក់ខ្មៅ គេសន្មតពណ៌សជាពេលរាំង ពណ៌ខ្មៅជាពេលភ្លៀង។ គេត្រូវចាប់ពិនិត្យសត្វនេះនៅពេលដើមឆ្នាំ គឺនៅខែពិសាខ។ បើឃើញខ្មៅច្រើនជាងស គេថាឆ្នាំនេះមានភ្លៀងច្រើន។ បើឃើញសច្រើនជាងខ្មៅ គេថាឆ្នាំនេះនឹងមានភ្លៀងធ្លាក់ចុះពុំបានគ្រប់គ្រាន់ឡើយ ។

នៅឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម អ្នកស្រុកមានការកត់ចំណាំចំពោះផ្កាត្នោត ដែលកំពុងស្រក់ទឹកចូលបំពង់ បើឃើញទឹកត្នោតដែលស្រក់តាំងពីផ្កានោះមានសភាពដូចជា សម្បុរ(សំបោ)ក្របី គេចំណាំថានឹងមានភ្លៀងធំធ្លាក់ឆាប់ៗនេះ ប៉ុន្តែបើផ្កាខ្មៅល្អវិញ គេថាមិនមានភ្លៀងធ្លាក់ទេ។

ម៉្យាងទៀត អ្នកនៅឃុំក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំថា គេមានការចំណាំដូច្នេះ បើពេលយប់ស្ងាត់ទៅហើយសត្វចិញ្ចឹមមាន គោ ក្របី ជ្រូក មាន់ ទា ជាដើម

ផ្អើលជ្រួលក្នុងទ្រុង បើដូចជាមានមនុស្សឬសត្វអ្វីធ្វើឲ្យវាភ័យ គេសំគាល់ថានឹងមានជម្ងឺសត្វឬជំងឺមនុស្សរាតត្បាតស្រុក។ មួយទៀតថា បើមានរាំងភ្លៀងយូរ ហើយសត្វក្អែកវាស្រែកកញ្ច្រោលញយៗ នោះគេចំណាំថា ស្រុកនឹងមានភ័យដោយជម្ងឺអុត ឬដោយមានកើតអសន្តិសុខ។

អ្នកស្រុកកំពង់ហ្លួង(កណ្តាល)ថា គេធ្លាប់យកប្រ-ផ្នូលទឹកធំឬតូច ដោយពិនិត្យមើលស្មៅបារាំងត្រង់ស្លឹកដែលមានជ្រួញ គឺថា បើជ្រួញនៅអែបនឹងគល់ស្លឹក គេថាទឹកតូច បើជ្រួញនៅពាក់កណ្តាលស្លឹក គេថា ទឹកមធ្យមបើជ្រួញនៅត្រង់ចុងស្លឹក គេថា ទឹកធំ។

តែបើចង់ដឹងថាទឹកនៅឡើង ឬត្រូវស្រកចុះទៅវិញនោះ អ្នកស្រុកច្រើនចំណាំមើលហេតុនៅពេលក្បាលដំឡើង គឺត្រូវមើល ៖

ក).សត្វមាន់ទឹក: បើឃើញសត្វនេះហើរបណ្តោយទន្លេ គេថា ទឹកធំ បើឃើញវាហើរទទឹងទន្លេ គេថា ទឹកលែងឡើងទៀតហើយ។

ខ).សត្វពពុះទឹក: នៅពេលព្រឹកព្រហាម បើសត្វ

ពពុះទឹកហើរបណ្តោយតាមទន្លេ គេថា ទឹកនៅឡើងទៀត បើសត្វនោះហើរច្រាសទឹក គេថា ទឹកស្រក។

គ).សត្វក្រពើ: កាលណាក្រពើដេកដាក់ក្បាលសំយុងទៅរកទឹក គេថា ទឹកធំ។ បើកាលណាវាដេកដាក់ក្បាលបែរមករកគោកវិញ គេថាទឹកតូច។

ឃ).សត្វគីង្គក់: បើកាលណាវាយំឮសូរកឹកៗ គេដឹងថា ទឹកឡើង។ តែបើវាយំឮសូរក្រេតៗទេ គេថា ទឹកស្រកវិញហើយ។

ង).សត្វឃ្មុំ: បើកាលណាគេចូលទៅក្នុងព្រៃ ហើយឃើញសត្វឃ្មុំធ្វើសំបុកនៅនឹងមែកឈើទាបៗ គេដឹងថា ឆ្នាំនេះ ទឹកតូចទេ។ បើឃ្មុំវាធ្វើសំបុកនៅពាក់កណ្តាលដើមឈើ គេថា ទឹកមធ្យម។ តែបើវាធ្វើសំបុកនៅមែកឈើ ខ្ពស់ៗ នោះគេនឹងដឹងថា ទឹកឆ្នាំនេះឡើងធំហើយ។

ច).សត្វទីទុយ: បើទឹកកំពុងឡើងខ្លាំង ហើយគេឮសត្វទីទុយយំ គេដឹងថា ទឹកនឹងស្រកវិញ ឬពុំនោះទេ គេថា ទឹកនៅនឹងមិនឡើងមិនស្រក។

ឆ).សត្វមាន់ចិញ្ចឹមៈ នៅរដូវដំឡើង បើមានទ្រុង ហើយវាមិនដេក វាបែរជាឡើងទៅលើចុងឈើវិញ គេថា ទឹកធំហើយឆ្នាំនេះ។ បើវាកាងស្លាបក៏គេចំណាំថា មាន ភ្លៀង។

ជ).សត្វស្រមោចៈ បើវាផ្ញើលជ្រួលច្រាល គេដឹងថា នឹងមានភ្លៀង បើគេឃើញកំពែងសម្បុកវាប៉ោងខ្ពស់ពី ខាងកើត គេដឹងថា ទឹកធំ។ បើកំពែងវាប៉ោងខ្ពស់ពីខាង លិច គេថា ទឹកតូច។

ឈ).សត្វកង្កែបៈ បើពេលកំពុងក្តៅខ្លាំង ហើយគេ ឮស្នូរសត្វកង្កែបយំ គេដឹងថា ជិតមានភ្លៀងធ្លាក់ហើយ។

ញ).សត្វរងាវកកៈ បើនៅពេលរាំង ហើយឮសត្វ រងាវកកហើរស្រែកកញ្ច្រៀវ គេដឹងថានឹងមានភ្លៀងធ្លាក់។

ដ).សត្វកុកៈ បើនៅពេលកំពុងភ្លៀងធ្លាក់ គេឃើញ សត្វកុកហើរកាត់ពីមុខភ្លៀង គេអាចដឹងថា ទឹកភ្លៀងធ្លាក់ តែត្រឹមកន្លែងដែលសត្វកុកហើរកាត់នោះទេ មិនរាលទៅ មុខទៀតឡើយ។

ឋ).ខ្យងៈ បើខ្យងបិទមាត់ជិត គេថាអស់ភ្លៀងហើយ

បានជាវាបៀមទឹកទុក ; បើមាត់វានៅហា គេថា នៅមានភ្លៀងទៀត។ ចំណែកឯអ្នកនៅជិតស្ទឹងវិញ បើកាលណាគេឮសត្វខ្យងក្តក់ គេសំគាល់ថា នឹងមានទឹកជន់ដោយសារទឹកភ្លៀងដែរ។ បើកាលណាគេឮសត្វវៃយំ គេចំណាំថា ទឹកនឹងស្រកចុះវិញ។ បើគេសង្កេតឃើញមានសត្វប្រវឹកលេងទឹកច្រើន គេដឹងថា ទឹកនឹងឡើងធំមិនខាន ។

មានជំនឿម្យ៉ាងទៀតរបស់ខ្មែរយើងថា កាលណាមានភ្លៀងធ្លាក់ច្រើនហួសប្រមាណ គេរកចេញទៅប្រកបការងារអ្វីមិនកើត បើចង់ឲ្យភ្លៀងនោះរាំង គេត្រូវរកមនុស្សស្រីដែលជាកូនពៅ ហើយឲ្យមនុស្សនោះយកស្នឹងមួយទៅបោះនៅលើក្បាលដំបូកណាមួយ ឬយកក្តាមទៅចងព្យួរនៅលើដើមឈើណាមួយ គេចំណាំថា បើធ្វើឧបកិច្ចបែបនេះ ភ្លៀងនឹងរាំងទៅវិញ។ តែបើកាលណាពុំមានភ្លៀងធ្លាក់វិញ អ្នកស្រុកតែងជឿថា មកអំពីមានមនុស្សចងកក្នុងស្រុក ឬថាស្រុកកើតចម្បាំង ព្រោះបុរាណតែងនិយាយថា "ចម្បាំងរាំងជល់" ហើយបើចង់ឲ្យមានភ្លៀង គេនាំគ្នាឧបកិច្ចសែងរូបអ្នកតាទម្លាក់ទឹក ពុំនោះទេ គេធ្វើពិធីសុំទឹកភ្លៀង ។

ចំពោះរឿងមាន់រងាវខុសពេល ដែលជាសញ្ញាថាទឹកជោរ និងសត្វគីង្គក់ក្រែត ដែលជាសញ្ញាថាមានភ្លៀងធ្លាក់នោះ មានរឿងព្រេងបូរាណមួយដំណាលថា៖

កាលណោះ មានសត្វគីង្គក់មួយលោតផ្លោតៗទៅជួបនឹងមាន់។ គីង្គក់សួរមាន់ថា : "បងមាន់! ខ្ញុំឆ្ងល់ណាស់ ចុះបងឯងម្ដេចក៏ដឹងថាទឹកជោរ បានជាបងឯងរងាវខុសពេលឲ្យគេដឹងថាទឹកជោរ?"

មាន់ឆ្លើយថា: "កាលនោះគឺមកពីខ្ញុំត្រជាក់បាទជើង បានជាខ្ញុំហ៊ានរងាវប្រាប់គេថា ទឹកជោរហើយ។ ចុះបងគីង្គក់ឯងម្ដេចក៏ដឹងថាជិតភ្លៀង ក្រែតប្រាប់គេឲ្យដឹងដែរ?"

គីង្គក់ឆ្លើយថា: "ខ្ញុំដឹងថាមានភ្លៀង ដោយខ្ញុំធ្ងន់ក្បាល ឱ្យតែកាលណាខ្ញុំក្រែតទៀងតែមានភ្លៀងប្រាកដ"។

ក្រោយមក ពេលដែលមាន់កំពង់ដេកលក់ គីង្គក់ទៅលបផ្ដុំបាទជើងមាន់ មាន់ដឹងថាត្រជាក់បាទជើង ហើយក៏ស្រែករងាវឡើង។ ឯគីង្គក់ឃើញមាន់ច្រឡំដូច្នោះ

សប្បាយចិត្តណាស់ ក៏ទះដៃសើចចំអក ហើយលោតរត់ទៅបាត់។

ថ្ងៃក្រោយមកទៀត មាន់ដើរទៅប្រទះឃើញគីង្គក់កំពុងដេកលក់ ក៏ជុះអាចម៍ដាក់ក្បាលគីង្គក់ គីង្គក់ធ្ងន់ក្បាល ក៏តាំងក្រត តែដល់បើកភ្នែកឡើងឃើញមាន់ ក៏ដឹងខ្លួនថា មាន់មកផ្ចាញ់ខ្លួនទេតើ? គីង្គក់មានសេចក្ដីអៀនខ្មាស់មាន់ជាខ្លាំង ហើយនឹកស្ដាយដោយជ្រុលគំនិតប្រាប់រឿងគេអស់ទៅហើយ ។

អំពីចំណាំភេទបណ្ដាលឱ្យដឹងថាភ្លៀងឬរាំង ស្រុកសុខសប្បាយ ឬមិនសុខនោះ អ្នកស្រុកតាកែវចំណាំដូច្នេះ ៖

បើកាលណាមេឃមានសម្បុរក្រហមឬលឿង គេហៅថា "មេឃស្វាហាលស្រូវ" ហើយគេសំគាល់ថា ជិតមានភ្លៀងធ្លាក់ហើយ(១) បើពេលភ្លៀងរួចហើយ មេឃស្រឡះផេង គេចំណាំថា មិនយូរទេនឹងមានភ្លៀងទៀត តែបើប្រែជាមិនភ្លៀងទេនោះ គឺត្រូវរាំងយូរ ។

---

(១)- អ្នកខ្លះថា នឹងរាំងទៅវិញ

បើកាលណាឃើញ សត្វជើងត្រុំក្រសាររនាល ឬលលកត្រដាងស្លាបហាលថ្ងៃ គេចំណាំថា នឹងមានភ្លៀងធ្លាក់យ៉ាងធំក្នុងថ្ងៃនោះ។ អ្នកស្រុកខ្លះថា បើចង់ដឹងរឿងទឹកភ្លៀង ឱ្យចំណាំមើលសត្វត្រីណាដែលសម្បុរស មានត្រីចង្វាជាដើម បើឃើញពងក្នុងពោះវាធំចង់ញាស់ គេថានឹងមានភ្លៀងធ្លាក់ឆាប់។ បើឃើញពងវានៅតូចនៅឡើយ គេថា នៅយូរទៀតបានមានភ្លៀងធ្លាក់។

ប៉ុន្តែបើនឹងមើលត្រី គេឱ្យមើលតែត្រីណាដែលពងគ្មានសំបុកដូចជា ត្រីត្រឱន សណ្ដាយ កែស ឆ្លាំង កញ្ចុះ និងត្រីចង្វាជាដើម។

ម្យ៉ាងទៀត បើកាលណាគេឃើញត្រីដែលនៅក្នុងថ្លុកក្នុងត្រពាំងណាដែលឆាប់គោកមុនគេនោះ ខំប្រឹងបំរះនទៀលទៅរកកន្លែងទឹកជ្រៅ អ្នកស្រុកសំគាល់ថា ជិតអស់ទឹកភ្លៀងហើយ ។

ត្រីព្រួល: អ្នកនៅក្បែរទន្លេ គេមើលត្រីព្រួល បើកាលណាវាចុះ គេថា ទឹកលែងឡើងហើយ ព្រោះត្រីព្រួល

វាមកពីថ្វាយបង្គំពុទ្ធបាទវិញហើយ។ នេះចំពោះសត្វក្នុងទឹក ។

ឯចំណែកសត្វលើគោក អ្នកស្រុកច្រើនសំគាល់ដូច្នេះ ៖

ក)- ពីងពាង: វានិយមធ្វើសំបុកនៅគុម្ពស្មៅ ឬនៅគុម្ពស្រូវ , ចាស់ៗតែងនិយាយថា ឱ្យតែពីងពាងដាក់ប្រតឹង (គឺវាធ្វើសំបុកផ្ងារ) នឹងរាំងភ្លៀងហើយ បើវាព័ទ្ធសំណាញ់បញ្ឈរ ថានៅមានភ្លៀងទៀតមិនទាន់អស់ទេ។

ខ)- ជន្លេន: ចាស់ៗឱ្យចំណាំដូច្នេះថា បើក្រោយពេលភ្លៀងធំ មានជន្លេនចេញពីរន្ធច្រើន ហើយឡើងមកស្លាប់លើដី លោកថា រាំងភ្លៀងហើយ ឱ្យកូនចៅនាំគ្នាប្រញាប់ទប់ទឹកស្រែទៅ។

គ)- មេភ្លៀង: តែកាលណាមានមេភ្លៀងចេញហើរច្រើន គេថាអស់ភ្លៀងដែរ។

ឃ)- មូស: ថាបើពុំទាន់មានភ្លៀងទេ ប៉ុន្តែស្រាប់តែមានមូសចេញច្រើន គេថា នឹងមានភ្លៀងធ្លាក់យ៉ាងធំ។តែ

បើមានមូសចេញច្រើនក្រោយភ្លៀងវិញ គេថានឹងរាំងភ្លៀងទៅវិញ។

ង)-សង្ការៈ បើវាកាយរន្ធរាក់ គេថា នៅមានភ្លៀងទៀត បើវាកាយរន្ធជ្រៅ គេថាអស់ភ្លៀងហើយ គេសម្គាល់រន្ធរាក់ជ្រៅនឹងគំនរអាចម៍ដីតិចឬច្រើន។

ច)- ទន្សងៈ បើកាលណាទន្សងឡើងពងលើដើមឈើ ឬលើកំពូលដំបូក គេដឹងថាមានទឹកជន់ ហើយទឹកទន្លេក៏ធំ ។

ឆ)- ត្រកួតៈ គេមើលដូចជាត្រកួតខ្យល់ដែរ គឺថាបើគល់កន្ទុយវាខ្មៅខ្លាំង គេថាភ្លៀងដើមឆ្នាំច្រើន។ បើខ្មៅចុងខ្លាំង គេថាភ្លៀងចុងឆ្នាំច្រើន ហើយភ្លៀងជូនទៀតផង ឯជង្គរដូងក៏មានចំណាំខ្មៅ ស ដូចជាកន្ទុយត្រកួតដែរ។

ជ)- ខ្វែកធំៈ បើពេលយប់ គេឮសូរខ្វែកធំយំឮសូរ "ខ្វក់! ខ្វក់" ហើយហើរពីទិសខាងលិច ទៅទិសខាងកើត គេសម្គាល់ថា អស់ទឹកភ្លៀងហើយ។ បើវាហើរពីទិសខាងកើត ទៅទិសខាងលិច ពីទិសខាងត្បូង ទៅទិសខាងជើង

ឬពីទិសខាងជើង ទៅទិសខាងត្បូងវិញ គេសម្គាល់ថាមិនទាន់អស់ទឹកភ្លៀងឬទឹកជន់ទេ។

ឈ)- ប្រវឹក: បើសត្វនេះវាឡើងពងចុងឈើខ្ពស់មានចុងត្នោតឬចុងដូងជាដើម គេសម្គាល់ថានឹងមានទឹកភ្លៀងច្រើន ហើយទឹកជន់ក៏ធំដែរ។

ញ)- ត្រដេវវិច: បើសត្វនេះពងនៅរន្ធដំបូក ក៏គេសម្គាល់ថាមានភ្លៀងច្រើនដែរ។

ដ)- កន្ធាទូក: ចំពោះសត្វនេះ ចាស់ៗតែងប្រាប់កូនចៅឲ្យមើលពងវានៅខែចេត្រ ពិសាខ ឬជេស្ឋ ដែលទើបនឹងមានភ្លៀងធ្លាក់ជាដំបូង ហើយមានដក់ទឹកនៅក្នុងស្រែ ឬត្រពាំង។ លោកបានទាំងចងក្រងជាកំណាព្យទុកផងថា:

កន្ធាទូកខ្លួនទាបរាបនៅដី ហើរស៊ីស្មៅខ្ចីខែដើមឆ្នាំ
ស៊ីរួចពងទុកជាចំណាំ ឲ្យអ្នកស្រុកចាំមើលទឹកភ្លៀង។
តិចច្រើនគង់ដឹងដំណឹងខ្លះ ព្រោះលោកជាន់ចាស់គេផ្ទាត់ផ្សៀង
តាមតម្រាព្រៃមិនឲ្យល្អៀង បើស្រុករាំងភ្លៀងគង់គេដឹង។
បើពងឡើងខ្ពស់ឆ្ងាយពីទឹក មានភ្លៀងសន្ធឹកជន់អូរស្ទឹង

បើពងក្ស្បែទឹកជាដំណឹង ថាភ្លៀងឆ្នាំហ្នឹងតិចតួចទេ។
ដោយហេតុខ្ញុំបាទបានពិនិត្យ អង្គិតមើលហេតុឃើញហូរហៃ
ចាស់ៗជាន់ដើមច្រើនពូកែ ធ្វើស្រែតាមភេទមិនសូវខុស។

ឋ) - កន្ធំរុយៈ បើឃើញសត្វកន្ធំរុយហើរខ្ពស់ៗ គេចំណាំថា ពុំទាន់មានភ្លៀងទេ បើឃើញវាហើរប៉ប្រ៉ះដី គេថា នឹងមានភ្លៀងធ្លាក់ឆាប់ៗហើយ។

តែសូមជំរាបថា អ្នកស្រុកខ្មែរយើងមិនមែនធ្វើការចំណាំតែលើសត្វទេ គេកត់សម្គាល់រហូតដល់ដើមឈើ និងអាកាសធាតុទៀតផង ដូចគេសម្គាល់ថា បើដើមសង្ឃ័រមិនទាន់ផ្លែផ្កា បើត្រួយអំពិលនៅលាស់ខ្ចីល្អ ហើយវែងៗ បើដើមស្រងៃមិនទាន់មូលដើមទេនោះ គឺថា ទឹកភ្លៀងមិនទាន់អស់ទេ។ បើមានកំប្លោកនិងសំណាត់អណ្តែតច្រើនតាមទន្លេ គេដឹងថា ទឹកធំ។

បើមានអំបោះព្រះ (ខ្លះហៅថា អំបោះខ្មោច) រសាត់ច្រើន គេចំណាំថា នឹងមិនមានទឹកភ្លៀងទេ[១]។ បើរាំង

(១) .អ្នកស្រុកក្រចេះថា បើអំបោះព្រះរសាត់ច្រើននៅខែបុស្ស ឬមាឃ បើកំពុងភ្លៀងនឹងរាំងវិញ ហើយថែមទាំងមានកើតជម្ងឺមនុស្ស និងសត្វផង ។

ភ្លៀងយូរថ្ងៃ ហើយស្រាប់តែមេឃងងឹត មានធ្លាក់ពពកមួយផ្ទត់ខ្មៅវែងស្តូក គេថានឹងមានភ្លៀងធំ ហើយមានខ្យល់ព្យុះផងមិនលែង ។

អ័ព្ទ: ចាស់ៗចំណាំថា បើអ័ព្ទចុះមកមុនភ្លៀង ថានៅមានភ្លៀងទៀត។ បើអ័ព្ទចុះមកក្រោយភ្លៀង ថានឹងរាំងភ្លៀងទៅវិញ បើអ័ព្ទចុះខែផល្គុន-ចែត្រ ថាស្រុកមិនស្រួល ឬរាំងភ្លៀង។

ទឹកសន្សើម: ចំពោះទឹកសន្សើម គេចំណាំថា បើមាន ទឹកសន្សើមច្រើននៅមុនពេលភ្លៀង ថាភ្លៀងនឹងរាំង បើទឹកសន្សើមធ្លាក់ច្រើនក្រោយពេលភ្លៀង ថានៅមានភ្លៀងធ្លាក់ទៀត។ ហើយបើពេលចុងឆ្នាំនេះមានទឹកសន្សើម ធ្លាក់ច្រើន ឆ្នាំមុខនឹងមានភ្លៀងធ្លាក់ច្រើនដែរ បើចុងឆ្នាំនេះមានទឹកសន្សើមធ្លាក់តិច ទឹកភ្លៀងឆ្នាំមុខក៏តិចដែរ។

ទឹកភ្លៀង: ចាស់ៗថា បើភ្លៀងរលឹមជាប់ច្រើនថ្ងៃ ហើយទើបមានភ្លៀងធំ លោកថា រាំងភ្លៀងហើយ។ បើក្តៅខ្លាំងយូរថ្ងៃ លោកថានឹងមានភ្លៀងយ៉ាងធំមិនខាន

ឡើយ។ បើភ្លៀងបើកថ្ងៃ គេក៏សំគាល់ថា នឹងមានភ្លៀងធំដែរ ។

ទឹកទន្លេៈ បើទឹកទន្លេល្អក់ គេសំគាល់ថា ទឹកនៅឡើង បើទឹកទន្លេថ្លា គេសំគាល់ថា ទឹកស្រកហើយ។

ព្រឹលៈ បើឆ្នាំណាភ្លៀង ហើយមានធ្លាក់ព្រឹល លោកចំណាំថា ឆ្នាំនោះច្រើនមានភ្លៀងល្អជូនតាមរដូវកាល។

ឥន្ទធនូៈ គេសំគាល់ថា បើឥន្ទធនូចុះទិសខាងលិចថានឹងមានភ្លៀងយ៉ាងធំ ត្រូវតែនាំគ្នាបើករង្វះស្រែឲ្យអស់។ ប៉ុន្តែបើឥន្ទធនូចុះទិសខាងកើតវិញ គេថានឹងឈប់ភ្លៀងហើយ ត្រូវបិទរង្វះយ៉ាងប្រញ៉ាប់។

ពពកៈ បើឃើញ "ជ្រលងដំរីស" ដែលជាជួរពពកសវែងសន្ធឹងលើមេឃ ពីជើងទៅត្បូង គេថា មិនទាន់មានភ្លៀងទេ បើ "ជ្រលងដំរីស" នោះសន្ធឹងចាក់ឈៀង ពីទិសព្យាសាន ទៅទិសត្បូង នោះជាប្រផ្នូលឲ្យដឹងថា នឹងមានភ្លៀងធ្លាក់ឆាប់ៗហើយ។ បើពេលព្រលឹម មេឃស្រឡះ ហើយគេឃើញនៅទិសខាងកើត មានពពកខ្មៅក្រាស់ពូនខ្ពស់ដូចភ្នំ អ្នកស្រុកហៅ "ភ្នំទឹក"។ តែបើ

ពពកពូននោះបង្ហាញនៅពេលល្ងាច នាទិសខាងលិចវិញ ហើយមានពណ៌លឿងក្លី សក្តី អ្នកស្រុកសំគាល់ថា ជា " ភ្នំស្រូវ " ទៅវិញ។

ផ្គរលាន់: នៅជិតពេលភ្ជុំបិណ្ឌ គេតែងឮសូរផ្គរ គ្រំៗនៅទិសខាងកើត ផ្គរនេះអ្នកស្រុកហៅថា "ផ្គរដំឡើងទឹក"។ ឯផ្គរលាន់នៅទិសអាគ្នេយ៍ នៅពេលក្រោយភ្ជុំ គេហៅថា "ផ្គរទឹកអង្ករបាក់"។ បើពេលភ្លៀងយប់នៅខែកត្តិកឬមិគសិរ ហើយឮសូរផ្គរលាន់ឆ្លើយឆ្លងគ្នា រវាងទិសខាងជើង និងទិសខាងត្បូង គេហៅថា " ផ្គរផ្តាំក្តាមខ្យង " ជាសញ្ញាឲ្យដឹងថា ជិតអស់ភ្លៀងហើយ ឲ្យក្តាមខ្យងកាយរន្ធឲ្យជ្រៅទៅទាន់ដីនៅទន់។ ពេលនោះ អ្នកធ្វើស្រែក៏បញ្ជាឲ្យកូនចៅទប់ទឹកស្រែឲ្យឆាប់ដែរ។

នៅខែកត្តិក ច្រើនមានភ្លៀងធ្លាក់ នៅពេលជិតភ្លឺ ហើយមានរន្ទះបាញ់ញាប់ផង ភ្លៀងធ្លាក់ខ្លាំងបីដូចគេចាក់ទឹក ពុំសូវមានខ្យល់ទេ អ្នកស្រុកតែងហៅថា" ភ្លៀងលាងស្លែ " និង " រន្ទះបាញ់ក្បាលក្រាញ់ " ព្រោះនៅរដូវនោះ

គេតែងសង្កេតឃើញត្រីក្រាញ់មានក្បាលរបកមួយដុំសៗ ដែលគេមិនដែលឃើញមាននៅរដូវឯទៀត ។

ក្រៅអំពីហេតុភេទ ដែលបណ្តាលឡើងអំពីធម្មជាតិជាប្រផ្នូល មានប្រផ្នូលទាយទឹកភ្លៀងម៉្យាងទៀត ដែលក្លាយទៅជាទំនៀម គឺជាពិធីសម្រក់ទៀនទាយទឹកភ្លៀង ដែលគេតែងធ្វើជាមួយគ្នានិងពិធីសំពះព្រះខែនៅថ្ងៃពេញបូរមីណ៍ខែកត្តិក ។

ពិធីជាតួយ៉ាង ដែលខ្ញុំនឹងលើកយកមកអធិប្បាយជូនមានសេចក្តីដូចតទៅ ៖

ទំនៀមពីបូរាណរៀងមក គេតែងធ្វើពិធីសំពះព្រះខែនិងអកអំបុកវេលាយប់ថ្ងៃពេញបូរមីណ៍ខែកត្តិក ដែលជារដូវអស់ភ្លៀងនៅទីវត្តអារាម។ នៅយប់ជាមួយគ្នានោះ នៅឃុំអង្គាញ់ [១] ស្រុកព្រៃកប្បាស ខែត្រតាកែវ អ្នកស្រុកនាំគ្នាទៅជួបជុំគ្នានៅទីវត្ត នៅវេលាម៉ោង៧យប់ ហើយ

---

១.តាមសេចក្តីរាយការណ៍របស់លោក ខួង អ៊ួច អតីតមេឃុំ ឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

នាំគ្នារៀបចំសំពះព្រះខែជាមុនសិន ទើបរៀបចំកន្លែងធ្វើពិធីសម្រក់ទៀនទាយទឹកភ្លៀងជាក្រោយ ។

លុះចប់ពិធីសំពះព្រះខែហើយ អ្នកស្រុកនាំគ្នារកបង្គោលឈើពីរមកដាំជាសសរនៅខាងកើតតុ ដែលគេដំកល់គ្រឿងសក្ការបូជាចំពោះព្រះច័ន្ទ ហើយយកឈើមួយទៀតមកចងទទឹង ភ្ជាប់នឹងបង្គោលទាំងពីរ កំពស់ពីដីប្រហែលជាមួយម៉ែត្រ។ ទើបយកទៀនក្រមួនសុទ្ធចំនួន៥ដើម ទៅបិទនឹងឈើទទឹង ឲ្យមានចម្ងាយពីមួយទៅមួយប្រហែលជាពីរតឹក។ ទៀនមួយៗមាន ទម្ងន់កន្លះដម្លឹង និងមានប្រវែងមួយចំអាម ទៀនទាំង៥នោះជានិមិត្តរូបនៃស្រុកចំនួន៥ ក្នុងខែត្រតាកែវ គឺគេសន្មតថា៖

ក)- ទៀនមួយដើមខាងត្បូងបំផុត ជាតំណាងស្រុកទ្រាំង។

ខ)- ទៀនទីពីរបន្ទាប់ ជាតំណាងស្រុកត្រាំកក់។

គ)- ទៀនកណ្ដាល ជាតំណាងស្រុកព្រៃកប្បាស គឺស្រុកដែលធ្វើពិធីនោះ។

ឃ)- ទៀនបន្ទាប់មកទៀត ជាតំណាងស្រុកសំរោង។

ង)- ទៀនខាងជើងបំផុត ជាដំណាងស្រុកបាទី។

រួចទើបគេយកស្លឹកចេក៤-៥ ផាងមកក្រាលនៅលើដីពីក្រោមទៀនទាំង៥នោះ សម្រាប់ត្រងក្រមួន ដែលហូរធ្លាក់ពីទៀន និងសម្រាប់មើលនិមិត្តរូប ដែលជាប្រផ្នូលផ្សេងៗដល់ស្រុកទេសផង ។

លុះរៀបចំស្រេចបាច់ហើយ មុននឹងអុជទៀន គេនិយាយបួងសួងរងំៗគ្រប់គ្នា សុំឲ្យការបូលមើលទឹកភ្លៀងនេះបានផុតដូចបំណង។ បន្ទាប់មកគេចាប់អុជទៀនទាំង៥នោះ ហើយគេទុកឲ្យទៀននោះឆេះល្មស្មើៗគ្នា ទើបគេចាប់ឈើទទឹងបង្វិលឲ្យទៀនសំយុងចុះក្រោម តែមិនឲ្យស៊ប់ទេ ឲ្យរាងទ្រេតបន្តិចទើបទៀនមិនរលត់។ ទៀនណាស្រក់ដើមដំបូងញាប់ ដល់ឆេះបានពាក់កណ្តាលទៅស្រក់រង្វើលវិញ ហើយដល់ជិតអស់ស្រក់ច្រើនទៀត គេសំគាល់ថា ស្រុកដែលទៀនជាតំណាងនោះ មានភ្លៀងដើមឆ្នាំច្រើន ដល់កណ្តាលឆ្នាំភ្លៀងតិច ហើយដល់ចុងឆ្នាំទើបមានភ្លៀងច្រើនវិញ។

កាលបើទៀននោះស្រក់អស់ហើយ ទើបគេយកស្លឹកចេក ដែលគេដាក់ត្រង់ដំណក់ក្រមួនមកបញ្ចាំងមើលរូប។ បើឃើញមានរូបប្រហែលសត្វនាគ គេទាយថា ឆ្នាំមុខនឹងមានភ្លៀងច្រើន (ព្រោះនាគជាអ្នកបង្អុរភ្លៀង)។ បើឃើញប្រហែលសត្វគ្រុត គេទាយថា ឆ្នាំមុខពុំសូវមាន ភ្លៀងទេ (ព្រោះនាគខ្លាចគ្រុឌ)។ បើឃើញរូបប្រហែល សត្វគោ ក្របី ដំរី គេទាយថា ស្រុកនឹងបានសុខសប្បាយ។ បើឃើញជារូប សេះ ខ្លា រមាស ពស់ ឬសត្វ ព្រៃដទៃ ទំនាយថានឹងមានកើតឧត្បាត និងជម្ងឺតម្កាត់ក្នុងស្រុក។ ប៉ុន្តែរឿងទំនាយទាំងនេះ ពុំមានក្បួនខ្នាតជាសំអាងទេ គ្រាន់តែជាការចំណាំរបស់អ្នកស្រុកតៗគ្នាមកប៉ុណ្ណោះ។

# តម្រាកំណត់ចំណាំរបស់កសិករខ្មែរ

ខ្ញុំបាទ សែម សុទ្ធ បច្ចុប្បន្នអាយុ៦៦ឆ្នាំ នៅភូមិស្ពើងជ័យ ឃុំស្ពើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ធ្លាប់បានចំណាំលើធម្មជាតិ តិណជាតិ សត្វបក្សី ផ្កាយជាដើម។

កាលពី៣០ឆ្នាំមុន ការកំណត់ចំណាំ ត្រូវបាន ៧០,៨០% ព្រោះបរិស្ថានធម្មជាតិ នៅគង់វង្សបានល្អ ១០០%។

តើឆ្នាំនេះទឹកធំឬតូច?

ក-កសិករមួយក្រុមសម្គាល់ចំណាំលើផ្កាយអូរ ជាផ្កាយមួយប្រភេទ រះតៗគ្នាវែង មានពន្លឺឆ្លុះតគ្នា លាតសន្ធឹងដ៏វែងលើផ្ទៃអាកាស មានសណ្ឋានទ្រង់ទ្រាយដូចជាអូរ ទើបបូរាណកសិករសន្មតឈ្មោះថា ផ្កាយអូរ។

កំណត់សម្គាល់ លើលក្ខណៈផ្កាយនោះ ទោះខាងរនោចឬខ្នើតនៃខែ ក្នុងរដូវវស្សាក្តី ក៏ការចំណាំមានន័យដូចគ្នា។ គឺគេចំណាំថា៖

ឆ្នាំនេះទឹកធំ ពេលក្បាលព្រលប់ នៅខាងខ្នើត ឬរនោចនៃខែ កាលណាផ្កាយអូររះទទឹងទិសពីខាងកើតទៅ

ខាងលិច គឺក្បាលនៅទិសខាងជើង កន្ទុយនៅទិសខាងត្បូង សន្មតថា ទឹកធំ។

- បើផ្កាយបែរក្បាលទៅទិសឦសាន្ត កន្ទុយទៅទិសនិរតី ទឹកមធ្យម។ បើផ្កាយរះបណ្ដោយទិស គឺពីទិសខាងកើតទៅទិសខាងលិច សន្មតថា ទឹកតូច។

ខ-កសិករមួយក្រុម សម្គាល់លើស្មៅៈ ស្មៅបារាំងច្រើនដុះនៅបឹង ទន្លេ ឯស្មៅកាំប្រមាច្រើនដុះនៅស្រែចំការ តែការចំណាំដូចគ្នា។

បើឆ្នាំនេះទឹកធំ មានភ្លៀងល្អទាំងបីរដូវ គឺដើមឆ្នាំកណ្ដាលឆ្នាំ និងចុងឆ្នាំ។ ស្លឹកស្មៅទាំងពីរប្រភេទនេះមានគន្លាក់ៗបីគន្លាក់ ពីគល់ស្លឹក កណ្ដាលស្លឹក និងចុងស្លឹក។

បើគល់ស្លឹកមាន កណ្ដាលគ្មាន ចុងមាន សន្មតថាឆ្នាំនេះដើមឆ្នាំមានភ្លៀងល្អ ចុងឆ្នាំល្អ កណ្ដាលឆ្នាំទ្រួសទ្រើយ។

បើគល់ស្លឹកគ្មាន កណ្ដាលមាន ចុងស្លឹកមាន ចំណាំឃើញថា ដើមឆ្នាំក្រទឹកភ្លៀង កណ្ដាលឆ្នាំភ្លៀងល្អ និងចុងឆ្នាំភ្លៀងល្អ។

កសិករដែលជាពុទ្ធសាសនិកក្នុងស្រុកបី គឺស្រុក

ជើងព្រៃ ស្រុកកំពង់សៀម ខេត្តកំពងចាម និងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ពុទ្ធសាសនិកទាំងបីស្រុកនេះសម្គាល់ទៀនព្រះខែ ក្នុងរដូវអកអំបុកសំពះព្រះខែប្រចាំឆ្នាំនីមួយៗ។

លក្ខណៈរបស់ទៀនព្រះខែ គេយកអំបោះឆៅ មកលុញនិងក្រមួនសុទ្ធ ទំហំប៉ុនមេដៃ ប្រវែងជាងពីរតឹក ចំនួនបីដើម។

យកទៀនទាំងបីដើម មកបិទលើដើមឫស្សីមួយដើមប្រវែងជាងពីរម៉ែត្រ ឃ្លាតពីគ្នាប្រវែងកន្លះម៉ែត្រមួយៗ ទុកខាងចុងឫស្សីប្រមាណកន្លះម៉ែត្រ សម្រាប់កាន់បង្វិលទៀនចុះឡើងតាមកាលកំណត់។ ក្នុងទៀនទាំងបីដើម ដែលបិទដង្ហែគ្នា ទៀននៅខាងចុងគេទិសខាងត្បូង គេសន្មតតំណាងស្រុកកំពង់សៀម ទៀននៅត្រង់កណ្ដាល សន្មតតំណាងស្រុកជើងព្រៃ ទៀនដែលនៅខាងចុង ទិសខាងជើងតំណាងស្រុកបារាយណ៍ ខេត្តកំពង់ធំ។

វិធីអុជទៀនព្រះខែ ពេលថ្ងៃពេញបូរមី១៥កើត ខែកត្តិក រៀងរាល់ឆ្នាំ វេលាម៉ោង១២យប់ ពេលព្រះខែត្រង់។ កម្មវិធីបង្វិលទៀនព្រះខែនេះ ពុទ្ធសាសនិកវត្តស្ដើងជ័យ

ឃុំស្ដើងជ័យ ស្រុកជើងព្រៃ នៅបន្តធ្វើរៀងរាល់ឆ្នាំ។ ចាស់ៗគាត់នៅមានជំនឿថាស័ក្តសិទ្ធិ៨០%។ មុនធ្វើកម្មវិធីបង្វិលទៀនព្រះខែនេះ គេយកស្លឹកចេកមួយផាងធំមកដាក់ខាងក្រោមដើមឫស្សីដែលបិទទៀន។ កាលបើដល់ពេលកំណត់ម៉ោងជិត១២អាធ្រាតហើយ ពុទ្ធបរិស័ទប្រុសស្រីជាច្រើន នមស្ការព្រះរតនត្រៃ សមាទាន រក្សានិច្ច-សីល និមន្តព្រះសង្ឃចំរើនព្រះបរិត្ត។ លុះចប់ព្រះបរិត្តលោកអាចារ្យ ធ្វើពិធីបួងសួង ដល់វត្ថុស័ក្តសិទ្ធិនិងវេលា-ហាកទេវបុត្រទាំងបីរក្សា ទឹកភ្លៀង និងខ្យល់ជាកសិណសាក្សី។ ក្នុងពិធី មានទាំងដង្វាយ ចេក អំបុក ដូង ជាដើមសម្រាប់បូជា។ លុះចប់ពិធីបូជា និងអធិដ្ឋានគុណព្រះរតនត្រៃរួចហើយ មានមនុស្សពីរនាក់ ជាអ្នកឈរកាន់ចុងឫស្សីម្ខាងម្នាក់ ចាំបង្វិលទៀនចុះឡើង តាមលោកអាចារ្យប្រកាសឱ្យអនុវត្តន៍។

កាលជាដំបូង ទៀននៅខាងលើឫស្សីទាំងបីដើម អាចារ្យឱ្យអ្នកកាន់ភ្លើងទៀនដែលឆេះ ចូលទៅឆួលអុជទៀនទាំងបីព្រមគ្នា លុះទៀនឆេះព្រមគ្នាហើយ ទុកឱ្យឆេះនៅស្ងៀមចំនួនបីនាទី ដើម្បីឱ្យទៀនឆេះស្មើគ្នាល្អ

លុះទៀនទាំងបីឆេះល្អហើយ អាចារ្យប្រកាសបង្វិលសាក លើកទី១ ឱ្យទៀនចុះក្បាលទៅក្រោម ប្រមាណបីនាទី ទើបបង្វិលទៀនឡើងលើវិញ។ លុះទៀនស្រក់ក្រមួនស្មើ ល្អហើយ ទើបអាចារ្យប្រកាសយកជាផ្លូវការលើកទី១ ម្តង ទៀតថា៖ សូមអនុមោទនា! អ្នកបង្វិលទៀនទាំងពីរនាក់ ក៏បង្វិលទៀនព្រមគ្នា ដាក់ភ្លើងចុះក្រោមបីនាទី រួចបង្វិល ឡើងលើវិញ វិធីនេះធ្វើគំរប់បីដង ក្រោមសម្លេងហោ កញ្ជ្រៀវយ៉ាងខ្ញៀវខ្ញារ គួរឱ្យរីករាយក្រៃលែង។ កំណត់ សម្គាល់លើទៀនឆេះ ហើយហូរដំណក់ទៀនស្រក់ច្រើន ជាងគេទាំងបីដង គឺដើមឆ្នាំល្អ កណ្តាលឆ្នាំល្អ ចុងឆ្នាំល្អ។ បើទៀនមិនសូវឆេះ ដំណក់ពុំសូវស្រក់ សន្មតថា ដើមឆ្នាំ ភ្លៀងទ្រូសទ្រើយ បើទៀនស្រក់ច្រើន កណ្តាលឆ្នាំភ្លៀង ល្អ ចុងឆ្នាំភ្លៀងល្អ។

ការចែកទៅតាមស្រុកទាំងបី គឺស្រុកកំពង់សៀមក្តី ស្រុកជើងព្រៃក្តី និងស្រុកបារាយណ៍ក្តី ក៏មានន័យដូច ទៀននីមួយៗ គឺថាស្រក់តិចឬច្រើនទាំងបីកាលនោះដែរ។

ឧទាហរណ៍: ដូចឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ទៀនព្រះខែបានបញ្ជាក់ថា នៅដើមឆ្នាំភ្លៀងទ្រូសទ្រើយ

កណ្ដាលឆ្នាំនិងចុងឆ្នាំភ្លៀងល្អ នៅស្រុកជើងព្រៃត្រូវ៩០% ស្រុកកំពង់សៀមត្រូវ៨០% ស្រុកបារាយណ៍ក៏ត្រូវ៨០% ដែរ។ ចំណែកស្លឹកចេកដែលដាក់នៅខាងក្រោមតំណក់ភ្លើងទៀននោះ មានរៀងដូចជាសត្វបង្កង។ ព្រឹទ្ធាចារ្យលោកបានកំណត់បញ្ជាក់ថា ឆ្នាំនេះសម្បូរទៅដោយមច្ឆាជាតិ។ ចំពោះទិន្នផលស្រូវកណ្ដាលថយផល ព្រោះច្រស់កំផើម ឯស្រូវធ្ងន់បានផលពេញលេញល្អ។

គ-កសិករខ្លះសម្គាល់លើលក្ខណៈ សត្វដង្កូវដូងដែលមាននៅក្នុងលាមកគោ លាមកក្របី កាលជីកជីយកទៅដាក់ស្រែ។ បើឆ្នាំនេះមានភ្លៀងល្អទាំងបីកាល សត្វ ដង្កូវដូងមានស្នាមអុចខ្មៅៗពីក្បាល កណ្ដាលខ្លួន និង កន្ទុយស្មើគ្នារហូត តែបើក្បាលគ្មានខ្មៅ ដើមឆ្នាំគ្មានភ្លៀង កណ្ដាលខ្លួនខ្មៅច្រើន ភ្លៀងល្អ ចុងកន្ទុយមានខ្មៅច្រើន ភ្លៀងច្រើន។ល។

ឃ-ពពួកសត្វបក្សីនិងសត្វឃ្មុំ ក្នុងខែ៦-៧នាដើមរដូវធ្វើស្រែ កាលបើសត្វបក្សីមាន ដូចជា ស្មោញ ប្រវឹក ក្អែកទឹក ក្ងាតទឹក ក្រសារ ជាដើមផ្ញើលហើរទាំងហ្វូងឡើងមកនៅលើសម្បុក ទុកដាក់ពងនិងកូននៅព្រៃស្រែ

ចម្ការ គេសន្មតថា ឆ្នាំនេះទឹកធំ ។ ម្យ៉ាងទៀត បើសត្វឃ្មុំ សត្វប្រវឹកធ្វើសម្បុកនិងបង្គងលើដើមឈើខ្ពស់ៗ ក៏សន្មតថា ទឹកធំដែរ។

បើសត្វឃ្មុំធ្វើសម្បុកនៅព្រៃនាមទាបៗ ហើយប្រវឹកធ្វើសម្បុកលើក្បាលទ្រក ឬតាមកំពោតព្រៃ ដូចទាព្រៃដែរ ឆ្នាំនេះសន្មតថា ទឹកតូច។

ការសម្គាល់ប្រចាំថ្ងៃ នៅរដូវវស្សាដើមឆ្នាំ បើពេលព្រឹក ពីម៉ោង៦ទៅម៉ោង៧ព្រឹក ថ្ងៃរះឡើងស្រឡះតាំងពីផ្ទៃដីចាំងឡើងទៅ មិនមានពពកកាត់ ពេលល្ងាចគឺ ភ្លៀងធំ។

ម្យ៉ាងទៀត ពេលព្រឹកមានពពកអណ្តែតរសាត់ពីទិសបូព៌ មករាយពាសពេញផ្ទៃមេឃទាបៗ នោះដល់ពេលល្ងាចក៏មានភ្លៀងធំដែរ។

បើពេលព្រឹកមានពពកទទឹងថ្ងៃ មិនព្រមរសាត់ទៅកាន់ទីដទៃ សន្មតចំណាំថា ថ្ងៃនេះគ្មានភ្លៀងទេ។

ចំណាំលើរដូវអស់ទឹកភ្លៀង សម្គាល់លើត្រីដណ្តើមគ្នាចុះតាមរង្វះទៅកាន់ទឹកជ្រៅ សន្មតថា អស់ទឹកភ្លៀងហើយ។

សម្គាល់លើរុក្ខជាតិ ដើមទន្រ្ទានខេត្តចេញផ្កាស សំពោង សន្មតថា អស់ទឹកភ្លៀងហើយដែរ។

ការកំណត់ចំណាំនៅ ព.ស.២៥៥៦នេះ ត្រូវបាន ៥០% ប៉ុណ្ណោះ ព្រោះបរិស្ថានធម្មជាតិត្រូវបានអភិវឌ្ឍន៍។

# ចប់ភាគទី១

## សូមរង់ចាំឆ្លងភាគបន្ត

## សូមអរគុណ!